# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សុន្ទរកថាបើក
## របស់កិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
## និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## ថ្លែងនៅក្នុង
## “សិក្ខាសាលាស្តីពីការបង្កើនភាពជាម្ចាស់លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ”
## រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥

- **ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
- **ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា នៃរាជរដ្ឋាភិបាល**
- **ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ជាទីមេត្រី !**

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោក លោកស្រី នៅក្នុងសិក្ខាសាលាស្តីពី “**ការបង្កើនភាពជាម្ចាស់លើ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**” នាឱកាសនេះ។ ខ្ញុំសូមចូលរួមជាមួយឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** ដើម្បីសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងសូមវាយតម្លៃខ្ពស់ចំពោះការរៀបចំ និងការចូលរួមយ៉ាង

សកម្មប្រកបដោយស្មារតីសហការ និងការទទួលខុសត្រូវខ្ពស់របស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមាននៅទីនេះ។

ដូចឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានគូសបញ្ជាក់ហើយថា ក្នុងរយៈកាល ១០ ឆ្នាំកន្លងទៅ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសម្រេចសមិទ្ធផលគួរជាទីលើកទឹកចិត្ត ដែលជាមូលដ្ឋានយ៉ាងសំខាន់ សម្រាប់ឈានទៅធ្វើការផ្លាស់ប្តូរប្រព័ន្ធតែម្តង គឺប្តូរ**ពីប្រព័ន្ធថវិកាផ្តោតលើមាតិកា ឬធាតុចូល និងមជ្ឈការទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬ ធាតុចេញ និងវិមជ្ឈការ** ស្របតាម “**ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ២០១៣-២០២០**” របស់រាជរដ្ឋាភិបាល។

ក្នុងន័យនេះ ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណចំពោះ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ក្នុងនាមឯកឧត្តមជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងឯកឧត្តម លោកជំទាវ ជាប្រធានក្រសួង ស្ថាប័នទាំងអស់ ដែលបានខិតខំចូលរួមចំណែកប្រកបដោយកិច្ចសហការ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការសម្រេចបានលទ្ធផលដ៏ធំធេង រហូតដល់ថ្ងៃនេះ។ សិក្ខាសាលារយៈពេល ១ ថ្ងៃនេះ នឹងបើក កាលានុវត្តភាពថ្មីមួយទៀត ដើម្បីចែករំលែកបទពិសោធន៍ និងស្វែងយល់ពីគ្នាទៅវិញទៅមក អំពីការកំណត់និងការរៀបចំផែនការសកម្មភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងប្រធានបទគន្លឹះមួយចំនួនទៀត សម្រាប់បោះជំហានទៅកាន់ជោគជ័យលើការកែទម្រង់ជាពិសេសការបណ្តុះឆន្ទៈប្តេជ្ញាកែទម្រង់, ការបង្កើនភាពជាម្ចាស់, និងការបំពាក់ស្មារតីនៃភាពចាំបាច់និងបន្ទាន់ក្នុងការកែទម្រង់។

ប្រាកដណាស់ថា សមិទ្ធផលនៃការអភិវឌ្ឍរបស់កម្ពុជាក្នុងរយៈពេល ១ ទសវត្សរ៍កន្លងទៅនេះ គឺជាសក្ខីភាពនៃការឈានទៅមុខរបស់កម្ពុជា ឆ្ពោះទៅរកស្ថិរភាពម៉ាក្រូ-សេដ្ឋកិច្ច ប្រកបដោយចីរភាព ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើនសេដ្ឋកិច្ច និងការ

ពង្រឹងលទ្ធិប្រជាធិបតេយ្យ, ការធានាបាននូវអធិបតេយ្យជាតិនិងបូរណភាពទឹកដី, ព្រមទាំងការអភិវឌ្ឍលើគ្រប់វិស័យ ទាំងនយោបាយ សេដ្ឋកិច្ច និងសង្គម។

ជាក់ស្តែង កម្ពុជាបានឆ្លងកាត់ដំណាក់កាលប្រវត្តិសាស្ត្រដ៏សំខាន់មួយ គឺដំណើរផ្លាស់ប្តូរស៊ីជម្រៅក្នុងគ្រប់ទិដ្ឋភាពនៃសង្គម ទន្ទឹមនឹងវប្បធម៌នយោបាយនិងប្រជាធិបតេយ្យកាន់តែឈានទៅរកភាពចាស់ទុំ ដែលបញ្ជាក់ឱ្យឃើញថា កម្ពុជាបាននិងកំពុងដើរលើផ្លូវត្រូវ ក្នុងការស្ថាបនានិងអភិវឌ្ឍប្រទេសជាតិ បម្រើបុព្វហេតុនៃឧត្តមប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។ ទោះយ៉ាងនេះក្តី កម្ពុជា នៅមានបញ្ហាប្រឈមមួយចំនួន ជាអាទិ៍ ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោក, ភាពជឿទុកចិត្តសមស្របពីសាធារណ-ជន មកលើសេវាសាធារណៈ, សមត្ថភាពស្ថាប័ននិងធនធានមនុស្ស សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម, ព្រមទាំងការកែទម្រង់រចនាសម្ព័ន្ធផ្ទៃក្នុងចាំបាច់ សម្រាប់ធ្វើសមា-ហរណកម្មទៅក្នុងតំបន់និងសកលលោក។ ប្រាកដណាស់ថា ដើម្បីឆ្លើយតបទៅនឹងកត្តាទាំងនេះ យើងពិតជាមិនអាចកាត់ផ្តាច់ចេញពីការកែលម្អនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានឡើយ ពីព្រោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មិនត្រឹមតែមានមុខងារស្វែងរកថវិកា វិភាជថវិកា និងធានាការប្រើប្រាស់ថវិកា ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពប៉ុណ្ណោះទេ ថែមទាំងមានតួនាទីជាឃ្នាស់សេដ្ឋកិច្ច និងជាឧបករណ៍ទ្រទ្រង់គោលនយោ-បាយសាធារណៈ របស់ជាតិ នៅគ្រប់ផ្នែក និងគ្រប់វិស័យទៀតផង។

ទន្ទឹមនេះ ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** បានគូសបញ្ជាក់អំពីករណីយកិច្ច ដែលយើងត្រូវពុះពារជម្នះបញ្ហាប្រឈម ការលំបាក និងភាពស្មុគស្មាញនានា ដែលកើតចេញពីការងារកែទម្រង់ ជាពិសេស ការបញ្ចប់ដំណាក់កាលទី២ និងការត្រៀមចាប់ផ្តើមដំណាក់កាលទី៣។ នៅក្នុងវឌ្ឍនាការនេះ សិទ្ធិអំណាចនិងការទទួលខុសត្រូវលើការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន នឹងត្រូវបង្កើនឡើងជាលំដាប់ ជាពិសេស នៅក្នុងដំណាក់កាលទី៣ ខាងមុខនេះ ដែលចាំបាច់តម្រូវឱ្យក្រសួង

ស្ថាប័ន បង្កើនសុឆន្ទៈប្តេជ្ញាកែទម្រង់ លើកកម្ពស់ភាពជាម្ចាស់ និងប្រកាន់ខ្ជាប់ស្មារតីទទួលខុសត្រូវ ទើបអាចប្រើប្រាស់សិទ្ធិអំណាច និងធានាទទួលខុសត្រូវបាន ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ខ្លួន។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី** !

ជាការពិត ការងារកែទម្រង់ ចៀសមិនផុតពីបញ្ហាប្រឈមឡើយ ទាំងនៅកម្រិតដឹកនាំ កម្រិតគ្រប់គ្រង និងកម្រិតប្រតិបត្តិការបច្ចេកទេស។ នេះពុំមែនជាបញ្ហាដោយឡែកសម្រាប់កម្ពុជាឡើយ នេះគឺជាបញ្ហាសកល ដែលប្រទេសនានាលើសកលលោក ធ្លាប់បានឆ្លងកាត់រួចមកហើយនៅលើវិថីកែទម្រង់របស់ខ្លួន។ ក្នុងចក្ខុវិស័យនេះ ខ្ញុំសូមគាំទ្រអនុសាសន៍ណែនាំរបស់ឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អូន ព័ន្ធមុនីរ័ត្ន** និងសូមលើកទឹកចិត្តឱ្យសមាជិក សមាជិកា នៃអង្គសិក្ខាសាលានាពេលនេះ មេត្តាយកចិត្តទុកដាក់អនុវត្តអនុសាសន៍ទាំងនេះ ឱ្យសម្រេចបាននូវផ្លែផ្កា ចេញជាផែនការសកម្មភាពលម្អិត យ៉ាងមានសង្គតិភាព និងពេញលេញគ្រប់ជ្រុងជ្រោយ ស្របតាមទិសស្លោករបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាគឺ “**កែទម្រង់ រស់, បើមិនកែទម្រង់ ស្លាប់**”។

ក្នុងនាមគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខ្ញុំសូមរំលឹកជាថ្មីម្តងទៀតអំពីភាពចាំបាច់នៃតួនាទីគន្លឹះ ជាតួអង្គនាំមុខរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងតួនាទីគន្លឹះជាតួអង្គអនុវត្ត របស់គ្រប់ក្រសួង ស្ថាប័ន ដែលតម្រូវឱ្យមានជាចាំបាច់នូវឆន្ទៈប្តេជ្ញាកែទម្រង់, បង្កើនភាពជាម្ចាស់, ពង្រឹងភាពជាអ្នកដឹកនាំ និងប្រកាន់ខ្ជាប់នូវស្មារតីទទួលខុសត្រូវខ្ពស់ តាមអភិក្រម បុរេសកម្ម សកម្ម និងអន្តរកម្ម ដែលជាបុរេលក្ខណៈសម្បត្តិ សម្រាប់ធានាជោគជ័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះថ្នាក់ដឹកនាំ និងមន្ត្រី

រាជការគ្រប់លំដាប់ថ្នាក់ នៃគ្រប់ក្រសួង ស្ថាប័ន ដែលបានជំរុញការអនុវត្ត "**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" ក្នុងរយៈពេលកន្លងទៅ និងសូមលើកទឹកចិត្តឱ្យបន្តឆន្ទៈកែទម្រង់, ភាពជាម្ចាស់, ស្មារតីទទួលខុសត្រូវ, កិច្ចខិតខំប្រឹងប្រែង និងការរួមចំណែក ព្រមទាំងកិច្ចសហប្រតិបត្តិការដ៏ល្អ កាន់តែរឹកដុះដាលរឹងមាំឡើងជាលំដាប់ សំដៅជំរុញអនុវត្ត "**បញ្ចប់ដំណាក់កាលទី២ និងឈានទៅចាប់ផ្តើមដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" ប្រកបដោយជោគជ័យតាមការរំពឹងទុក ក្នុងបុព្វហេតុបម្រើឧត្តមប្រយោជន៍ប្រទេសជាតិនិងប្រជាពលរដ្ឋកម្ពុជា។

ខ្ញុំសូមប្រសិទ្ធពរបវរមហាប្រសើរជូនចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ សិរីមង្គល វិបុលភាព ជាភិយ្យោភាព និងសម្រេចបានជោគជ័យគ្រប់ភារកិច្ចរៀងៗខ្លួន តាមការប្រគល់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាពិសេសទទួលបាននូវជោគជ័យ និងលទ្ធផលជាផ្លែផ្កាពីសិក្ខាសាលានេះ។

ខ្ញុំរួមជាមួយឯកឧត្តមបណ្ឌិតរដ្ឋមន្ត្រី **អ៊ូន ព័ន្ធមុនីរ័ត្ន** និងគណៈអធិបតី សូមប្រកាសជាផ្លូវការបើក **សិក្ខាសាលាស្តីពីការបង្កើនភាពជាម្ចាស់លើការងារកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ** ចាប់ពីពេលនេះតទៅ។

*សូមអរគុណ!*